

# ព្រះគាថាធម្មបទ ៣៧ គាថា

# ព្រះគាថាធម្មបទ ៣៧ គាថា

*ព្រះគាថានេះ ព្រះអង្គទ្រង់ប្រារព្ធចំពោះ*
*លាជទេពធីតា*

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសស្ត្រីធ្វើបុណ្យ គប្បីធ្វើបុណ្យនោះ ឲ្យបានរឿយៗ និងគប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងបុណ្យនោះផង ព្រោះការសន្សំបុណ្យ នាំមកនូវសេចក្ដីសុខ ។

*ទ្រង់ប្រារព្ធចំពោះចូឡេកសាដកព្រាហ្មណ៍*

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ**

**ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ ធ្វើនូវអំពើល្អ គប្បីហាមឃាត់ចិត្ត ចាកបាប ព្រោះថា បើបុគ្គលធ្វើសេចក្តីល្អយឺតយូរ ចិត្តរមែងត្រេកអរនឹងបាប ។

ទ្រង់ប្រារព្ធចំពោះធម្មិកឧបាសក

**ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

បុគ្គលដែលបានធ្វើបុណ្យទុកហើយ រមែងរីករាយត្រេកអរ ក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះផង រីករាយក្នុងលោកខាងមុខផង បុគ្គលនោះរមែងត្រេកអរ រីករាយ ព្រោះឃើញនូវអំពើ ដ៏បរិសុទ្ធរបស់ខ្លួន ។

ទ្រង់ប្រារព្ធចំពោះនាងវិសាខា

**យថាបិ បុប្ផរាសិម្ហា   កយិរា មាលាគុណេ ពហូ**
**ឯវំ ជាតេន មច្ចេន   កត្តព្វំ  កុសលំ  ពហុំ ។**

នាយមាលាការ គប្បីធ្វើកម្រងផ្កាឲ្យបានច្រើន អំពីគំនរនៃផ្កា យ៉ាងណា សត្វលោកកើតមកហើយ មានសេចក្តីស្លាប់ ជាធម្មតា គប្បីធ្វើកុសលឲ្យបានច្រើន ក៏យ៉ាងនោះដែរ ។

ទ្រង់ប្រារព្ធចំពោះនាយសុមនមាលាការ

**តញ្ច កម្មំ កតំ សាធុ   យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ   វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ មិនក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ មានការឆ្អែតចិត្ត មានចិត្ត

សប្បាយរីករាយ សោយនូវផលនៃកម្មណា កម្ម នោះ ជាកម្មល្អ ។

ទ្រង់ប្រារព្ធចំពោះព្រះអង្គុលិមាល

**យស្ស បាបំ កតំ កម្មំ កុសលេន បិធីយតិ**
**សោ មំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

បុគ្គលណា ធ្វើអំពើបាបហើយ បិទអំពើបាបនោះ ដោយកុសល បុគ្គលនោះ ឈ្មោះថា រមែងញុំាង នូវលោកនេះ ឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទ្រ រះផុតចាកពពក ។

ទ្រង់ប្រារព្ធចំពោះនាងឧត្តរា

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីឈ្នះមនុស្សក្រោធ ដោយការមិនក្រោធ
តប គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្តីល្អ គប្បី
ឈ្នះមនុស្សកំណាញ់ ដោយការឲ្យ គប្បីឈ្នះ
មនុស្សនិយាយមិនពិត ដោយនិយាយពាក្យពិត ។

ទ្រង់ប្រារព្ធចំពោះនាយកុក្កុដមិត្ត

**បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ**
**នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។**

បើដំបៅ មិនមានលើបាតដៃទេ បុគ្គលគប្បីកាន់
យកថ្នាំពិស នឹងបាតដៃបាន ថ្នាំពិសមិនអាចជ្រាប
ចូលទៅកាន់បាតដៃ ដែលមិនមានដំបៅបានយ៉ាង
ណាមិញ បាបក៏មិនមានដល់អ្នកដែលមិនធ្វើបាប
ក៏យ៉ាងនោះដែរ ។

ទ្រង់ប្រារព្ធចំពោះចុល្លកាលឧបាសក

**អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ**
**អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។**

បុគ្គលណាធ្វើបាប ដោយខ្លួនឯង បុគ្គលនោះ រមែងសៅហ្មង ដោយខ្លួនឯង បុគ្គលណា មិនធ្វើបាបដោយខ្លួនឯង បុគ្គលនោះ នឹងបរិសុទ្ធដោយខ្លួនឯង សេចក្តីបរិសុទ្ធ និងសេចក្តីមិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃ នឹងធ្វើឲ្យអ្នកដទៃ បរិសុទ្ធមិនបានឡើយ ។

ទ្រង់ប្រារព្ធចំពោះមហាកាលឧបាសក

**អត្តនា ហិ កតំ បាបំ អត្រជំ អត្តសម្ភវំ**
**អភិមត្ថតិ ទុម្មេធំ វជិរំ វម្ហយំ មណឹ ។**

បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី ដែលកើតអំពីថ្មនោះឯង ។

ទ្រង់ប្រារព្ធចំពោះឆព្វគ្គិយភិក្ខុ

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយ សុទ្ធតែតក់ស្លុតចំពោះអាជ្ញា សត្វទាំងឡាយ សុទ្ធតែភ័យខ្លាច ចំពោះសេចក្ដីស្លាប់ ( គ្រប់ៗ គ្នា ) បុគ្គលធ្វើខ្លួនឲ្យជាឧបមាហើយ មិន

គួរប្រហារ ដោយខ្លួនឯង មិនគួរប្រើអ្នកដទៃ ឲ្យប្រហារនូវសត្វដទៃឡើយ ។

ទ្រង់ប្រារព្ធចំពោះឆព្វគ្គិយភិក្ខុ

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយ សុទ្ធតែតក់ស្លុតចំពោះអាជ្ញា សត្វទាំងឡាយ សុទ្ធតែស្រឡាញ់ជីវិតរបស់ខ្លួន ( គ្រប់ៗគ្នា ) បុគ្គលធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃ ឲ្យប្រហារ នូវសត្វដទៃឡើយ ។

ទ្រង់ប្រារព្ធចំពោះនាយកាឡៈ

**បឋព្យា ឯករជ្ជេន សគ្គស្ស គមនេន វា**
**សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។**

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរជាងភាពឯករាជលើផែនដី ជាងដំណើរទៅកាន់ឋានសួគ៌ និងប្រសើរជាងអធិបតីភាព ក្នុងលោកទាំងមូល ។

ទ្រង់ប្រារព្ធចំពោះលោឡុទាយី

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយ មានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិលច្រអូស ជាមន្ទិល នៃពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិល នៃអ្នករក្សា ។

ទ្រង់ប្រារព្ធចំពោះមាតាព្រះកុមារកស្សប

**អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។**

ខ្លួនជាទីពឹង របស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលមានខ្លួនទូន្មានល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

ទ្រង់ប្រារព្ធចំពោះបាជិកាជីវក

**ន បរេសំ វិលោមានិ ន បរេសំ កតាកតំ**
**អត្តនោវ អវេក្ខេយ្យ កតានិ អកតានិ ច ។**

ពាក្យចាក់ដោត របស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ជនដទៃ បុគ្គលមិនគួរពិនិត្យមើលទេ

បុគ្គលគួរពិនិត្យ ពិចារណា តែកិច្ចទាំងឡាយដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

ទ្រង់ប្រារព្ធធីតានៃជាងតម្បាញម្នាក់

**អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ**
**សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។**

លោកិយមហាជននេះ ងងឹតណាស់ ដូចជាមនុស្សខ្វាក់ ក្នុងលោកនេះ មានមនុស្សតិចនាក់ណាស់ ដែលបានដឹងច្បាស់នូវបញ្ញក្ខន្ធតាមពិត តិចនាក់ណាស់ ដែលទៅកាន់ស្ថានសួគ៌ ដូចបក្សីដែលជាប់សំណាញ់ របស់ព្រានហើយ តិចណាស់ដែលអាចរួចអំពីសំណាញ់បាន ។

ទ្រង់ប្រារព្ធចំពោះពោធិរាជកុមារ

**អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ ( របស់ខ្លួន ) គួររក្សាខ្លួននោះ ឲ្យល្អ គួរស្ងួនគ្រងខ្លួនទុក ក្នុងវ័យទាំង ៣ វ័យណាមួយ ។

ទ្រង់ប្រារព្ធចំពោះអសទិសទាន

**ន វេ កទរិយា ទេវលោកំ វជន្តិ**
**ពាលា ហវេ នប្បសំសន្តិ ទានំ**
**ធីរោ ច ទានំ អនុមោទមានោ**
**តេនេវ សោ ហោតិ សុខី បរត្ថ ។**

បុគ្គលកំណាញ់ ស្វិតស្វាញ មិនបានទៅកាន់ទេវលោកឡើយ ជនពាលទាំងឡាយ មិនសរសើរនូវការឲ្យទានទេ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោករមែងបានសុខ ក្នុងលោកខាងមុខ ។

ទ្រង់ប្រារព្ធចំពោះឧបាសក ៥ នាក់

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។**

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ ស្មើដោយទោសៈមិនមាន សំណាញ់ស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

ទ្រង់ប្រារព្ធចំពោះនាយពាណិជ

**វាណិជោវ ភយំ មគ្គំ  អប្បសត្ថោ មហទ្ធនោ**
**វិសំ  ជីវិតុកាមោវ  បាបានិ  បរិវជ្ជយេ ។**

បុគ្គលគួរចៀសវាងបាបទាំងឡាយ  ឲ្យដូចនាយពាណិជ  ដែលមានទ្រព្យច្រើន  តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច  ឬដូចជាបុរស ប្រាថ្នាការរស់នៅ ចៀសវាងថ្នាំពិស ដូច្នោះដែរ ។

ទ្រង់ប្រារព្ធចំពោះភិក្ខុកំលោះ

**ហីនំ ធម្មំ ន សេវេយ្យ     បមាទេន  ន  សំវសេ**
**មិច្ឆាទិដ្ឋឹ  ន  សេវេយ្យ   ន សិយា លោកវឌ្ឍនោ ។**

បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ  មិនគួរសេពមិច្ឆាទិដ្ឋិ  មិនគួរជា

មនុស្ស ចង្អៀតលោកឡើយ ។

ទ្រង់ប្រារព្ធចំពោះនាយព្រានសុនខ ឈ្មោះកោក:

**យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ**

**សុទ្ធស្ស បោសស្ស អនង្គណស្ស**

**តមេវ ពាលំ បច្ចេតិ បាបំ**

**សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេស ដូចជាទីទួល បាបរមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចជាធូលីល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ដូច្នោះ ។

ទ្រង់ប្រារព្ធចំពោះអានន្ទសេដ្ឋី

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

ជនពាលតែងព្រួយលំបាក ដោយសេចក្ដីសំគាល់ថា កូនទាំងឡាយ របស់អញមាន ទ្រព្យរបស់អញមាន តាមពិត សូម្បីខ្លួន របស់ខ្លួន ក៏មិនមានចំណាំងបើកូនទាំងឡាយ នឹងរាប់ថាមាន អំពីណាបាន ទ្រព្យនឹងរាប់ថាមាន អំពីណាបាន ។

ទ្រង់ប្រារព្ធចំពោះដំរីបាវេរកៈ

**អប្បមាទរតា ហោថ សចិត្តមនុរក្ខថ**
**ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។**

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ ចូរតាមរក្សាចិត្ត របស់ខ្លួន ចូរស្រង់ខ្លួនឡើងចាកភក់ ( គឺកិលេស ) ដូចជាដំរីដែលជាប់ភក់ ហើយខំប្រឹង ស្រង់ខ្លួនរួចបាន ដូច្នោះឯង ។

ទ្រង់ប្រារព្ធចំពោះព្រះបាទបសេនទិកោសល

**អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ**
**វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។**

ការមិនមានរោគ ជាលាភយ៉ាងក្រៃលែង សេចក្ដីសន្ដោស ជាលាភដ៏ប្រសើរ សេចក្ដីស្និទ្ធស្នាល ជាញាតិយ៉ាងក្រៃលែង ព្រះនិព្វាន ជាសុខដ៏ឧត្តម ។

ទ្រង់ប្រារព្ធចំពោះឧក្កណ្ឋិតភិក្ខុ ( ភិក្ខុអផ្សុក )

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញា គប្បីរក្សាចិត្ត ដែលឃើញបាន ដោយកម្រក្រៃពេក ដែលល្អិតបំផុត មានប្រក្រតី ធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ជាទីត្រេកអរ ( ព្រោះថា ) ចិត្តដែលបុគ្គលឃុំគ្រងល្អហើយ រមែងនាំមកនូវសេចក្តីសុខ ។

ទ្រង់ប្រារព្ធចំពោះភិក្ខុ ៥០០ រូប

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

ការកើតឡើង នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ ការសម្តែងព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នា របស់សង្ឃ ឬពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមដុតនូវកិលេស របស់អ្នកដែលព្រមព្រៀងគ្នា នាំមកនូវសេចក្តីសុខ ។

ទ្រង់ប្រារព្ធចំពោះព្រះបាទបសេនទិកោសល
និងបុរសម្នាក់

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។**

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រលឹក ( អ្នកដេកមិនលក់ ) យោជន៍វែងចំពោះតែអ្នកនឿយហត់ ( ស្បើយកម្លាំង ) សង្សារវដ្តវែងឆ្ងាយ ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

ព្រះអង្គទ្រង់ប្រារព្ធចំពោះឧទាយិភិក្ខុ

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ**
**ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។**

បុគ្គលពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតបានដឹងរសធម៌ តាមសេចក្តីពិត ដូចវែកមិនដឹងរសសម្ល ដូច្នោះ ។

ព្រះអង្គទ្រង់ប្រារព្ធពួកភិក្ខុក្រុងបាវា

**មុហុត្តម្បិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ**
**ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។**

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងដឹងច្បាស់ធម៌ ដោយឆាប់រហ័ស ដូចអណ្តាតដឹងរសសម្ល ដូច្នោះ ។

ព្រះអង្គទ្រង់ប្រារព្ធចំពោះព្រះតិស្សភិក្ខុ

**បវិវេករសំ បិត្វា រសំ ឧបសមស្ស ច**
**និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិ រសំ បិវំ ។**

បុគ្គលបានក្រេបផឹកនូវរស ដែលកើតអំពីវិវេក និង រសព្រះនិព្វាន ដែលចូលទៅស្ងប់រម្ងាប់កិលេស បានក្រេបផឹកនូវរសបីតិ ដែលកើតអំពីធម៌ ជាអ្នក មិនមានសេចក្ដីក្រហល់ក្រហាយ មិនមានបាប ។

ទ្រង់ប្រារព្ធចំពោះភិក្ខុមួយរូប

**ទុន្និគ្គហស្ស លហុនោ យត្ថកាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្ត ដែលគេសង្កត់សង្កិនបានដោយ លំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅ

ក្នុងអារម្មណ៍ តាមសេចក្តីប្រាថ្នា រមែងជាគុណជាតញុាំងប្រយោជន៍ឲ្យសម្រេច ( ព្រោះថា ) ចិត្តដែលទូន្មានបានហើយ រមែងនាំមកនូវសេចក្តីសុខមកឲ្យ ។

ទ្រង់ប្រារព្ធចំពោះព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

ជនទាំងឡាយណា សង្រួមចិត្តដែលត្រាច់ទៅឆ្ងាយ ត្រាច់ទៅតែឯង គ្មានសរីរៈ រាងកាយ មានគុហា គឺមហាភូតរូប ជាទីអាស្រ័យនៅ ជនទាំងឡាយនោះ នឹងបានរួចផុតអំពីចំណងរបស់មារ ។

ទ្រង់ប្រារព្ធចំពោះសង្កិច្ចសាមណេរ

**យោ ច វស្សសតំ ជីវេ**
**ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ**
**សីលវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្ត សីល មានចិត្ត មិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃរបស់អ្នក ដែលមានសីល មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

ទ្រង់ប្រារព្ធចំពោះឧបាសកមួយរូប

**ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា**
**ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ។**

សេចក្ដីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង ( អ្នកប្រាជ្ញ ) ដឹងច្បាស់សេចក្ដីនុ៎ះ តាមពិតហើយ ( រមែងធ្វើឲ្យជាក់ច្បាស់ ) នូវព្រះនិព្វាន ដែលជាសុខយ៉ាងក្រៃលែង ។

ទ្រង់ប្រារព្ធចំពោះមដ្ឋកុណ្ឌលី

**មនោបុព្វង្គមា ធម្មា  មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន  ភាសតិ វា  ករោតិ វា**
**តតោ នំ សុខមន្វេតិ  ឆាយាវ អនុបាយិនី ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្ដី ធ្វើក្ដី ( នូវសុចរិត ) ព្រោះ

សុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចជាស្រមោលអន្ទោលតាមប្រាណ ។

## អធិប្បាយបាទនៃព្រះគាថាធម្មបទ

***សុខោ បុញ្ញស្ស ឧច្ចយោ*** ការសន្សំបុណ្យ តែងនាំមកនូវសេចក្ដីសុខ ។

បុណ្យជាមិត្តល្អ នាំសុខមកឲ្យ សុខទាំងឡាយ ក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។ បានជាព្រះពុទ្ធ ព្រះពុទ្ធមាតា ព្រះពុទ្ធបិតា កន្សែរសារពេជ្ជ ឯតទគ្គបុគ្គល ។ល។ ព្រោះបុណ្យនាំឲ្យបានសម្រេចទាំងអស់ គឺបុណ្យជាឧបនិស្ស័យនៃសេចក្ដីសម្រេចនោះៗ ។

ព្រោះហេតុដូច្នេះ បុគ្គលត្រូវធ្វើបុណ្យឲ្យរឿយៗ កុំល្មមក្នុងបុណ្យ ធ្វើទាំងការពេញចិត្ត ពេញកម្លាំង ព្រោះបុណ្យ ដែលបុគ្គលសន្សំហើយ តែងនាំមកនូវសេចក្ដីសុខ ។

***អភិត្ថរេថ កល្យាណេ*** *បុគ្គលគួរប្រញាប់ប្រញាល់ ធ្វើអំពើល្អ ។*

*បានជាប្រញាប់ធ្វើអំពើល្អ ព្រោះមកអំពីប្រញាប់ហាមឃាត់ចិត្តចាកបាប ដូចជាបុគ្គល ត្រូវភ្លើងឆេះហើយប្រញាប់លត់ភ្លើងនោះ ដូច្នោះឯង ។*

*ធម្មជាតិចិត្ត រមែងសម្បូណ៌ទៅដោយបាបមិត្ត មានសេចក្តីកំណាញ់ ការច្រណែន ការលុបគុណ កាមច្ឆន្ទៈ និងព្យាបាទជាដើម ព្រោះហេតុដូច្នេះ កាលបើបុគ្គលធ្វើបុណ្យ ដោយកម្លាំងទន់ខ្សោយ ឬ យឺតយ៉ាវ ចិត្តរមែងត្រូវបាបមិត្តអូសទាញឲ្យលិចលង់ក្នុងអន្លង់បាបកម្ម ។*

***អត្តានំ ឧបមំ កត្វា*** *បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ។*

*សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុត នឹងអាជ្ញាការវាយដំ ព្យាបាទ បៀតបៀន និងខ្លាចចំពោះសេចក្តីស្លាប់ដ៏យ៉ាងក្រៃលែង បុគ្គលគួរធ្វើខ្លួនឯង ឲ្យជាឧបមា*

មិនគប្បីប្រហារ មិនគប្បីបៀតបៀន នូវសត្វទាំងឡាយ ឡើយ ។

ជីវិតជាទីស្រឡាញ់ ជាទីហួងហែងដ៏ក្រៃលែង នៃសត្វទាំងឡាយ គ្រប់ជីវិតប្រាថ្នាសុខ ប្រាថ្នាការរស់នៅជាមួយនឹងបុគ្គលជាទីស្រឡាញ់ ជាមួយនឹងទ្រព្យសម្បត្តិ និង សេចក្តីប្រសើរគ្រប់យ៉ាង ។ បុគ្គលគួរមានខ្លួនឯងជាគ្រឿងប្រៀបធៀប គួរអប់រំមេត្តាចិត្ត ។

**សោតាបត្តិផលំ វរំ** សោតាបត្តិផល ជាគុណជាតប្រសើរជាង ( សម្បត្តិទាំងពួង លើលោក ) ។

ព្រះរាជា សូម្បីសោយរាជសម្បត្តិ ជាស្តេចចក្រពត្តិ ក៏ជាអ្នកមិនអាចរួចផុតអំពីនរកជាដើមបានឡើយ ចំណែកព្រះសោតាបន្ន ជាអ្នកមានទ្វារអបាយភូមិបិទហើយ សូម្បីមានកម្លាំងអន់ថយជាងព្រះសោតាបន្នទាំងអស់ ( ព្រះសោតាបន្ន ៣ ជំពូក គឺ សត្តក្ខត្តុំបរមៈ ១ កោលំកោលៈ ១ ឯកពីជី ១ ជំពូកដំបូងមានកម្លាំងអន់ថយជាង ២

ដំពូក ខាងចុង ) ក៏មិនកើតក្នុងភពទី ៨ ព្រោះហេតុនោះ សោតាបត្តិផលនុ៎ះឯង ទើបប្រសើរជាង គឺខ្ពស់បំផុត ។

**បមាទោ រក្ខតោ មលំ** សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

អ្នករក្សាគោ កាលបើធ្វេសប្រហែស គោរមែងចុះស៊ីសន្ទូងខ្លួនឯង ឬ សន្ទូងអ្នកដទៃ ពុំនោះសោត គោចូលព្រៃជួបក្តីអន្តរាយផ្សេងៗ យ៉ាងណាមិញ ការរក្សាចិត្តគ្រប់គ្រងទ្វារ ៦ ក៏ដូច្នោះដែរ អារម្មណ៍ ៦ ដូចជាសន្ទូងចំណែកពាលធម៌ដែលជាបាបមិត្តរបស់ចិត្ត ដូចជាព្រៃដែលពេញដោយគ្រោះថ្នាក់ផ្សេងៗ មានគ្រោះថ្នាក់ដោយសត្វសាហាវជាដើម ចំណែកស្មារតី ដូចជាអ្នករក្សាគោរីឯចិត្តដូចជាគោ ។

**អត្តា ហិ អត្តនោ នាថោ** ខ្លួនជាទីពឹងនៃខ្លួនឯង ។

ពាក្យថា **នាថោ** គឺជាទីពឹងពំនាក់ ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះទុកថា បុគ្គលតាំងនៅក្នុងខ្លួន គឺសម្បូណ៌ហើយដោយខ្លួន ដែលខ្លួនអាចនឹងធ្វើកុសលហើយបានឋានសួគ៌ ឬដើម្បីញ៉ាំងមគ្គ ឲ្យចម្រើន ជាក់ច្បាស់នូវអរិយផល ( អត្តសម្បទា ) ព្រោះហេតុនោះឯង ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន ។

**នត្ថិ រាគសមោ អគ្គិ** ភ្លើងស្មើដោយរាគៈ មិនមាន ។

ភ្លើងអាចញ៉ាំងកប្ប ឲ្យវិនាសបាន ប៉ុន្តែយូរៗ ម្តងប៉ុណ្ណោះ ឯចំណែកភ្លើងរាគៈវិញនោះ ឆេះអស់កាលជានិច្ច ម្យ៉ាងទៀត ភ្លើងខាងក្រៅក្តៅណាស់ឆេះចំពោះរូបតែប៉ុណ្ណោះ ចំណែករាគៈដុតឆេះកុសលធម៌ផ្សេងៗ ឲ្យវិនាសបាត់បង់អស់ ។

**បាបានិ បរិវជ្ជយេ** បុគ្គលគួរចៀសវាង នូវបាបទាំងឡាយ ។

អ្នកដំនួញមានទ្រព្យច្រើន មានគ្នាតិច កាលដែលធ្វើដំណើរតាមផ្លូវ ដឹងថាខាងមុខមានពួកចោរ ត្រូវតែកុំទៅ ឬ ត្រូវចៀសវាងរកផ្លូវសុវត្ថិភាព យ៉ាងណាមិញ បុគ្គលត្រូវតែចៀសវាងនូវបាបទាំងពួង យ៉ាងនោះដែរ ។

ម្យ៉ាងទៀត បុគ្គលគួរចៀសវាងនូវបាបទាំងឡាយឲ្យដូចជាអ្នកប្រាថ្នាការរស់នៅ ចៀសវាងការផឹកនូវថ្នាំពិសដូច្នោះដែរ ។

បុគ្គលខ្លាចពៀរវេរា គប្បីចៀសវាងនូវបាបកម្មទាំងឡាយ ។

**ហីនំ ធម្មំ ន សេវេយ្យ** បុគ្គលមិនគួរសេពធម៌ថោកទាប ។

បទថា **ហីនំ ធម្មំ** ក្នុងទីនេះ ជាឈ្មោះនៃកាមគុណ ៥ ព្រោះកាមគុណ ៥ ជារបស់ថោក សូម្បីសត្វតិរច្ឆានក៏សេពបាន ទាំងជាធម៌នាំសត្វទៅកើតក្នុងទីទាប មាននរកជាដើមទៀតផង ។

មនុស្សយើង គួរសេពគប់ជាមួយសទ្ធា សតិ ហិរិ និង ឱត្តប្បៈជាដើម ព្រោះគុណធម៌ទាំងអស់នេះ នាំឲ្យយើង បានខ្ពង់ខ្ពស់ នាំឲ្យយើងបានបញ្ញា រួចអំពីធម៌ថោកគ្រប់ យ៉ាង រុងរឿងដូចព្រះចន្ទរួចផុតពីពពកខ្មៅ ។

អធិប្បាយព្រះគាថា **ទុន្និគ្គហស្ស លហុនោ**

ធម្មតាចិត្ត ជាធម្មជាតដែលបុគ្គលសង្កត់សង្កិន បាន ដោយកម្រ ព្រោះហេតុនោះ ទើបឈ្មោះថា **ទុន្និគ្គហំ** ។ ចិត្តនេះ រមែងកើត និងរលត់ទៅយ៉ាងរហ័ស ព្រោះ ហេតុនោះ ទើបឈ្មោះថា **លហុ** ជាធម្មជាតដែលបុគ្គល សង្កត់សង្កិនបានដោយកម្រ ដែលជាធម្មជាតប្រព្រឹត្ត ទៅយ៉ាងរហ័ស ( កើតរលត់យ៉ាងរហ័ស ) ។

បាទព្រះគាថាថា **យត្ថកាមនិបាតិនោ** សេចក្តីថា មានប្រក្រតីធ្លាក់ចុះទៅ ក្នុងអារម្មណ៍ណាទីមួយ នោះ ឯង ។ ពិតណាស់ ចិត្តនេះរមែងមិនដឹងនូវឋានៈ ដែល ខ្លួនគួរបាន ឬឋានៈដែលមិនគួរបាន, ឋានៈដែលសមគួរ

ឬឋានៈដែល មិនសមគួរ រមែងមិនពិចារណាមើលជាតិ មិនពិចារណាមើលគោត្រ មិនពិចារណាមើលវ័យ, រមែងធ្លាក់ចុះទៅ ក្នុងអារម្មណ៍ តាមសេចក្ដីប្រាថ្នាបាន តែម្យ៉ាង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "មានប្រក្រតីធ្លាក់ចុះទៅក្នុងអារម្មណ៍ តាមសេចក្ដីប្រាថ្នា" ។

ការទូន្មានចិត្តបែបនេះ ទុំះជាការល្អ គឺការដែលបុគ្គលទូន្មានចិត្ត ដោយអរិយមគ្គ ៤ បានដល់ ធ្វើយសជាការល្អ ជាគុណជាត ញុំាំងប្រយោជន៍ឲ្យ សម្រេច ។

-សួរថា ព្រោះហេតុអ្វី ?

-ឆ្លើយថា ព្រោះថា ចិត្តដែលបុគ្គលទូន្មានបានហើយ រមែងនាំមកនូវសេចក្ដីសុខ គឺថា ចិត្តដែលបុគ្គលទូន្មានហើយ បានដល់ ធ្វើឲ្យអស់យស រមែងនាំមកនូវសេចក្ដីសុខដែលកើតអំពីមគ្គផល និងសេចក្ដីសុខ គឺព្រះនិព្វានដែលជាបរមត្ថ ។

**ចិត្តំ រក្ខេថ មេធាវី** អ្នកមានប្រាជ្ញា គប្បីរក្សាចិត្ត

ជនអន្ធពាលមិនមានបញ្ញា គឺថា អាចរក្សាចិត្តរបស់ខ្លួនបាននោះ រមែងមិនមានឡើយ ។ ជនអន្ធពាល តែងប្រព្រឹត្តទៅ ក្នុងអំណាចនៃអកុសលចិត្ត រមែងដល់នូវសេចក្តីវិនាស ។

បុគ្គលជាអ្នកមានបញ្ញា គឺជាបណ្ឌិតពិតប្រាកដ រមែងរក្សាចិត្ត គ្រប់គ្រងចិត្តទុកបាន ។ ព្រោះហេតុនោះ ក្នុងនាមជាពុទ្ធបរិស័ទ គប្បីបំពេញតួនាទីរបស់ខ្លួន គឺការគ្រប់គ្រងចិត្តខ្លួនឯង ព្រោះថា ចិត្តដែលគ្រប់គ្រងបានល្អហើយ ជាហេតុឲ្យសម្រេចនូវបរមសុខ ។

**សុខោ ពុទ្ធានមុប្បាទោ** ការកើតឡើង នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ ។

វៀរលែងតែព្រះបច្ចេកពុទ្ធចេញ សត្វលោកទាំងអស់សុទ្ធតែសម្រេចមគ្គផលដល់ព្រះនិព្វាន ដោយអាស្រ័យការត្រាស់ដឹង នៃព្រះសម្មាសម្ពុទ្ធទាំងអស់ ។ ព្រះធម៌

ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែង អស្ចារ្យណាស់ ធ្វើឲ្យអ្នកស្ដាប់ដោយល្អ បាននូវបញ្ញា ដូច្នេះ ពុទ្ធបរិស័ទគួរតែព្រមព្រៀងគ្នារក្សាព្រះពុទ្ធសាសនា ហើយប្រព្រឹត្តធម៌ដោយខ្លួនឯង កុំរវល់តែចាប់កំហុសអ្នកដទៃ ត្រូវពិចារណាវិបាកកម្មរបស់ខ្លួន និង តក់ស្លុតចំពោះអកុសលក្នុងចិត្តខ្លួនឯង ។

**ជិឃច្ឆា បរមា រោគា** ការស្រេកឃ្លាន គឺជារោគយ៉ាងក្រៃលែង ។

បើរោគដទៃ រក្សាម្ដងក៏ជាសះស្បើយ ឬថា បុគ្គលអាចកម្ចាត់បង់បាន ឯចំណែកការស្រេកឃ្លានវិញ ត្រូវរក្សាអស់កាលជានិច្ច ។

**និព្វានំ បរមំ សុខំ** ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង

ព្រះនិព្វាន ជាបរមសុខ ព្រោះការអស់ទៅនៃទុក្ខទាំងពួង ព្រះនិព្វានគឺជាទុក្ខនិរោធអរិយសច្ច ។ ពាក្យថាទុក្ខទាំងពួង គឺជាវដ្ដសង្សារដែលសន្មតថាជាយើង ថា

ជាគេម្នាក់ៗ រៀងៗ ខ្លួនហ្នឹងឯង ។ វដ្តសង្សារ គឺជាតំណ នៃខន្ធ មួយខណៈៗ អស់ពីមួយជាតិ តមួយជាតិ ដោយ មិនដឹងទីបំផុតខាងដើមពីត្រឹមណាមក ត្រូវបញ្ចប់ដោយ អរហត្តមគ្គ និងទីបំផុតនៃសង្សារត្រឹមការបរិនិព្វានរបស់ ព្រះអរហន្ត អស់ជាតិ អស់កំណើត ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា នាមរូបរលត់អស់ មិនមានសេសសល់ ព្រោះការរលត់ទៅនៃវិញ្ញាណ ៗ៚

